THE RBH NETWORK

# JOINT STATEMENT

Responsible Business Helpdesks (RBH) inform, sensitize, and advise companies in their respective countries on CSDD regulations and sustainable supply chains. The RBH are hosted by local business organisations and are part of a global network.

**The RBH Network – steered by GIZ GmbH**

Supported by:

IGS INITIATIVE FOR GLOBAL SOLIDARITY

**សេចក្តីព្រាង** (កំពុងកែសម្រួលការរចនា)

# សេចក្តីថ្លែងការណ៍រួមរបស់បណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ( RBH Network )

## សារសំខាន់ៗសម្រាប់ការអនុវត្តដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) ប្រកបដោយយុត្តិធម៌ និងជោគជ័យនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល

### *បរិបទ*

ចំនួននៃបទប្បញ្ញត្តិ និងគោលនយោបាយដែលកំណត់ថា ការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) គឺជាកាតព្វកិច្ចត្រូវអនុវត្តកាន់តែមានការកើនឡើង ដោយមានគោលបំណងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់អវិជ្ជមាននៃប្រតិបត្តិការអាជីវកម្មមកលើមនុស្ស និងបរិស្ថាននៅជុំវិញពិភពលោក។ ប្រសិទ្ធភាពរំពឹងទុកនៃដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) ដូចដែលបានកំណត់ដោយអង្គការសហប្រជាជាតិ និងបានដាក់ឱ្យប្រតិបត្តិការដោយអង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) ផ្តល់នូវឱកាស និងអត្ថប្រយោជន៍ជាច្រើនដល់បណ្តាក្រុមហ៊ុន និងសហគមន៍។ មានសូចនាករដ៏រឹងមាំជាច្រើនបង្ហាញឱ្យឃើញថា អ្នកផ្គត់ផ្គង់ដែលអនុវត្តវិធីសាស្រ្តត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) អាចបង្កើនលទ្ធភាពចូលទីផ្សារ និងកសាងទំនាក់ទំនងជាមួយនឹងអ្នកទិញបានកាន់តែរឹងមាំ។ ការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងដ៏រឹងមាំមួយ ដើម្បីតាមដានត្រួតពិនិត្យ និងលើកកម្ពស់លទ្ធផលការងាររបស់ក្រុមហ៊ុនចំពោះផ្នែកសង្គម និងបរិស្ថាន បង្ហាញអំពីធាតុផ្សំមួយក្នុងការពង្រឹងសមត្ថភាពប្រកួតប្រជែង វិជ្ជាជីវៈ និងការត្រៀមរួចរាល់ក្នុងការនាំចេញ ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យម។ សហគមន៍មូលដ្ឋាននានាទទួលបានអត្ថប្រយោជន៍ពីលក្ខខណ្ឌការងារល្អប្រសើរ និងបរិស្ថានកាន់តែផ្តល់សុខភាពល្អ។ ស្របពេលជាមួយគ្នានេះដែរ ជាការចាំបាច់ណាស់ដែលត្រូវទទួលស្គាល់ថា ការអនុវត្តដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) នាំមកនូវដំណើរការផ្លាស់ប្តូរដ៏សំខាន់បំផុតមួយសម្រាប់ដៃគូខ្សែច្រវាក់ផ្គត់ផ្គង់ ដែលនាំមកជាមួយនូវបញ្ហាប្រឈមមួយចំនួនផងដែរ។

### *អំពីសេចក្តីថ្លែងការណ៍*

នៅក្នុងសេចក្តីថ្លែងការណ៍រួមនេះ យើងខ្ញុំដែលជាសមាគមធុរកិច្ច និងសភាពាណិជ្ជកម្មចំនួនប្រាំបួនមកពីប្រាំពីរប្រទេស[1] និងជាសមាជិកនៃបណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH Network) សូមលើកឡើងនូវសារសំខាន់ៗចំនួនប្រាំសម្រាប់ការអនុវត្តដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃសិទ្ធិមនុស្ស និងបរិស្ថាន (HREDD) ប្រកបដោយជោគជ័យនៅក្នុងបណ្តាប្រទេសផលិត។ ក្នុងនាមជាសមាជិកនៃបណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH Network) យើងខ្ញុំតំណាងឱ្យជាង 500,000 ក្រុមហ៊ុននៅទូទាំងពិភពលោក ដែលមកពីបណ្តាវិស័យខុសៗគ្នាជាច្រើនដូចជា វាយនភណ្ឌ និងកាត់ដេរ រថយន្ត អេឡិចត្រូនិក គីមី ថាមពល រ៉ែ ឬកសិកម្ម។ យើងខ្ញុំសូមអំពាវនាវដល់និយ័តករ និងក្រុមហ៊ុនបញ្ជាទិញ ឱ្យប្រឹងប្រែងពង្រឹងការអនុវត្តច្បាប់បច្ចុប្បន្ន និងអនាគត ដោយធ្វើយ៉ាងណាផ្តោតលើប្រសិទ្ធភាព និងគោលការណ៍ទំនួលខុសត្រូវរួមគ្នា។

យើងខ្ញុំជឿជាក់ថា ការចូលរួមនៅក្នុងកិច្ចសន្ទនាដោយបើកចំហ និងស្មោះត្រង់អំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមនៃការអនុវត្តដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) នៅក្នុងបណ្តាប្រទេសផលិតសំខាន់ៗមួយចំនួននៃខ្សែច្រវាក់ផ្គត់ផ្គង់សកល ពិតជាមានសារៈសំខាន់ណាស់។ យោងតាមបទពិសោធផ្ទាល់របស់យើងខ្ញុំនៅក្នុងការធ្វើការជាមួយអ្នកផ្គត់ផ្គង់ក្នុងស្រុក សមាជិកនៃបណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH Network) បានបង្កើតគោលជំហររួមគ្នាមួយអំពីចំណុចដែលចាំបាច់ ក្នុងការធានានូវការអនុវត្តដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) ឱ្យបានជោគជ័យនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល។

> ***បណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH Network)***
>
> *មជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH) ផ្តល់ព័ត៌មាន ធ្វើឱ្យមានការឆ្លើយតប និងណែនាំដល់ក្រុមហ៊ុននានានៅក្នុងបណ្តាប្រទេសពាក់ព័ន្ធអំពីបទប្បញ្ញត្តិស្តីពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) និងខ្សែច្រវាក់ផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព។ មជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ គឺគ្រប់គ្រងដោយអង្គភាពធុរកិច្ចក្នុងស្រុក។ ការរៀនសូត្រ ការគាំទ្រ និងការផ្លាស់ប្តូរព័ត៌មានរួមគ្នា គឺធានាបានតាមរយៈបណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ដែលមានមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវជាសមាជិក។ រហូតមកដល់បច្ចុប្បន្ននេះ (ថ្ងៃទី 17 ខែកញ្ញា ឆ្នាំ2024) អ្នកផ្គត់ផ្គង់ជាង 1,300 បានប្រើប្រាស់ព័ត៌មាន និងសេវាប្រឹក្សារបស់សមាជិកនៃបណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ និងភាគីពាក់ព័ន្ធជាង 4,000 នាក់បានចូលរួមនៅក្នុងសន្និសីទ កិច្ចសន្ទនា ឬការបណ្តុះបណ្តាលជាង 90 ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ។*
>
> សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ ព្រឹត្តិបត្រព័ត៌មានរបស់មជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ

[1] បង់ក្លាដេស កម្ពុជា ម៉ិកស៊ិក ស៊ែប ទុយនេស៊ី ទួរគី និងវៀតណាម

# សារសំខាន់

## 1 ការអនុវត្តដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) ជាទំនួលខុសត្រូវរួម ដូច្នេះថ្លៃចំណាយ និងបន្ទុក ត្រូវបែងចែកឱ្យបានស្មើភាពគ្នានៅក្នុងចំណោមដៃគូខ្សែច្រវាក់ផ្គត់ផ្គង់

បន្ថែមពីលើលក្ខខណ្ឌតម្រូវតាមផ្នែកច្បាប់របស់រដ្ឋ អ្នកទិញជាច្រើនស្នើសុំឱ្យដៃគូខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួនប្រកាន់ខ្ជាប់តាមបទដ្ឋានសង្គម និងបរិស្ថាន ឧទាហរណ៍ តាមរយៈក្រមប្រតិបត្តិ ដែលជារឿយៗមានការធានា និងការផ្ទៀងផ្ទាត់អនុលោមភាពតាមរយៈការព្រមព្រៀងជាកិច្ចសន្យា កម្រងសំណួរសម្រាប់អ្នកផ្គត់ផ្គង់ ឬការធ្វើសវនកម្ម។ ការអនុវត្តនេះទំនងជាផ្លាស់ប្តូរហានិភ័យ និងបន្ទុកចំណាយទៅលើអនុលោមភាពទៅអ្នកផ្គត់ផ្គង់វិញ ហើយបានបង្ហាញថាការអនុវត្តនេះពុំសូវមានប្រសិទ្ធភាពនៅក្នុងការដោះស្រាយមូលហេតុបណ្តាលឱ្យមានចន្លោះខ្វះខាត[2]នៅក្នុងអនុលោមភាពឡើយ។ ដើម្បីសម្រេចគោលដៅរួមនៃការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានមកលើមនុស្ស និងបរិស្ថាន ត្រូវមានការលើកកម្ពស់ការយល់ដឹងក្នុងចំណោមដៃគូខ្សែច្រវាក់ផ្គត់ផ្គង់ទាំងអស់ជាបន្ទាន់ ដើម្បីឱ្យបានដឹងថា ដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) ទាមទារឱ្យមានកិច្ចសហការស្មើភាពគ្នា និងមិនមែនគ្រាន់តែជាការបង្វែរហានិភ័យ និងវិធានការពីលើចុះក្រោមនោះទេ ដែលជាក់ស្តែង ការអនុវត្តបែបនេះបណ្តាលឱ្យមានការអនុវត្តកិច្ចដដែលៗ និងមិនចាំបាច់។ ការយល់ដឹងថាដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) គឺមិនមែនជាបទដ្ឋានបន្ថែមដែលកំណត់ដោយអ្នកទិញនោះទេ ប៉ុន្តែគឺជាវិធីសាស្រ្តគ្រប់គ្រងជាប្រព័ន្ធ និងអាចសម្រេចបានដោយជោគជ័យបានតាមរយៈកិច្ចខិតខំប្រឹងប្រែងសហការគ្នា ដើម្បីជាប្រយោជន៍ដល់ដៃគូទាំងអស់ គឺទាមទារឱ្យមានការផ្លាស់ប្តូរសំខាន់ៗទៅលើលំនាំខ្សែច្រវាក់ផ្គត់ផ្គង់ទាំងមូល។ បណ្តាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH Network) លើកកម្ពស់វិធីសាស្រ្តការទទួលខុសត្រូវរួមក្នុងចំណោមភាគីពាក់ព័ន្ធនានានៅក្នុងបណ្តាប្រទេសផលិតកម្ម ហើយការយល់ដឹងនេះគឺចាំបាច់សម្រាប់ភាគីពាក់ព័ន្ធទាំងអស់ដែលចូលរួម។

→ *(អនុសាសន៍ 1.1.) យើងសូមឱ្យនិយ័តករពង្រឹងការអនុវត្ត និងសុំឱ្យអ្នកទិញលើកកម្ពស់ការយល់ដឹងអំពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDD) ដែលរួមបញ្ចូលនូវគោលគំនិត "ទំនួលខុសត្រូវរួម" ជាពិសេសការចែករំលែកថ្លៃចំណាយ និងបន្ទុកដោយស្មើភាពគ្នា។*

ការធ្វើឱ្យលក្ខខណ្ឌការងារប្រសើរឡើង និងការកាត់បន្ថយផលប៉ះពាល់បរិស្ថាន មិនមែនបានមកដោយមិនមានការចំណាយរបស់អ្នកផ្គត់ផ្គង់នោះទេ។ ការកែសម្រួលកម្រិតប្រាក់ឈ្នួល ដើម្បីអាចទូទាត់ប្រាក់ឈ្នួលសម្រាប់ចិញ្ចឹមជីវិតបាន ឬការដំឡើងសមត្ថភាពគ្រឿងម៉ាស៊ីន ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិច គ្រាន់តែជាឧទាហរណ៍ខ្លះៗអំពីវិធានការដែលទាមទារឱ្យមានការវិនិយោគហិរញ្ញវត្ថុរយៈពេលខ្លី និងរយៈពេលវែងយ៉ាងច្រើន។ ជារឿយៗ អ្នកផ្គត់ផ្គង់តម្រូវឱ្យលះបង់ពេលវេលា និងធនធានជាច្រើនក្នុងការផ្តល់ព័ត៌មានដល់អ្នកទិញអំពីប្រតិបត្តិការរបស់ខ្លួន និងត្រូវធ្វើសវនកម្មឯករាជ្យ ដើម្បីជាការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ។ កិច្ចខិតខំប្រឹងប្រែងដដែលៗ និងដែលមិនចាំបាច់ មួយចំនួនដែលជាតម្រូវការរបស់ក្រុមហ៊ុនផលិតដើម្បីបំពេញតាមតម្រូវការរបស់អតិថិជនរបស់ខ្លួន បានបង្វែរធនធានចេញពីការវិនិយោគទៅលើការធ្វើឱ្យលក្ខខណ្ឌការងារ[3]ប្រសើរឡើង ដែលជាធនធានដ៏មានតម្លៃ។ យើងខ្ញុំសូមស្វាគមន៍យ៉ាងមុតមាំចំពោះសេចក្តីណែនាំស្តីពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDDD) របស់សហភាពអឺរ៉ុបដែលដាក់ឱ្យអនុវត្តនាពេលខាងមុខនេះ ដែល តម្រូវឱ្យអ្នកទិញរ៉ាប់រងថ្លៃចំណាយសម្រាប់ការផ្ទៀងផ្ទាត់របស់ភាគីទីបីឯករាជ្យទៅលើសហគ្រាសធុនតូច និងមធ្យម ដែលរួមចំណែកដល់ការបែងចែកថ្លៃចំណាយ និងអនុលោមភាព[4] កាន់តែស្មើភាពគ្នា។

## 2 ដោះស្រាយហានិភ័យសង្គម និងបរិស្ថានតាមរយៈការអនុវត្តការទិញ

> *"ដៃគូខ្សែច្រវាក់ផ្គត់ផ្គង់ជាច្រើននៅតែយល់ឃើញថា HREDD គឺជាសំណុំលក្ខខណ្ឌតម្រូវបន្ថែមដែលត្រូវអនុវត្តដើម្បីបំពេញតាមបំណងរបស់អតិថិជន។"* – អ្នកគ្រប់គ្រងម្នាក់នៃអ្នកគ្រប់គ្រង RBH

សមត្ថភាពរបស់អ្នកផ្គត់ផ្គង់ក្នុងការបំពេញការរំពឹងទុក និងបទដ្ឋានសង្គម និងបរិស្ថាន ជាញឹកញាប់ទទួលរងឥទ្ធិពលពីការអនុវត្តការទិញរបស់អ្នកទិញ។ ឧទាហរណ៍ នៅក្នុងឧស្សាហកម្មសម្លៀកបំពាក់ ក្រុមហ៊ុនផលិតជាធម្មតាទទួលរងសម្ពាធ ក្នុងការផ្តល់ផលិតកម្មតម្លៃទាប និងបត់បែនខ្លាំង ហើយស្របពេលជាមួយគ្នានេះដែរត្រូវធានានូវការប្រកាន់ខ្ជាប់[5]តាមបទដ្ឋានសង្គម (និងបរិស្ថាន)។

ដូចនេះ យោងតាមវិធីសាស្រ្តទំនួលខុសត្រូវរួម ចំពោះដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDDD) ជាការសំខាន់ណាស់ដែលក្រុមហ៊ុនបញ្ជាទិញ ត្រូវវាយតម្លៃទំនាក់ទំនងនៃការ

---

[2] សូមមើលផងដែរ៖ Kuruvilla (2021)៖ បទប្បញ្ញត្តិឯកជនស្តីពីបទដ្ឋានការងារនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល - បញ្ហា វឌ្ឍនភាព និងសក្តានុពល

[3] សូមមើលផងដែរ៖ បណ្តាញ STAR Network (2024)៖ ការដោះស្រាយបញ្ហាសវនកម្ម៖ ការពិត បញ្ហាប្រឈម និងសេចក្តីអំពាវនាវ

[4] សេចក្តីណែនាំស្តីពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្មរបស់សហភាពអឺរ៉ុប មាត្រា 10.5 មាត្រា 11.6

[5] សូមមើលផងដែរ៖ គំនិតផ្តួចផ្តើមស្តីពីលក្ខខណ្ឌពាណិជ្ជកម្មប្រកបដោយនិរន្តរភាព (2022)៖ សៀវភៅសស្តីពីនិយមន័យ និងការអនុវត្តអនុលោមភាពពាណិជ្ជកម្ម

អនុវត្តការទិញរបស់ខ្លួន ដូចជាការកំណត់តម្លៃ និងរយៈពេលបញ្ចប់នៃដំណើរការនានា ទៅនឹងហានិភ័យពលកម្ម និងបរិស្ថាននៅខាងអ្នកផ្គត់ផ្គង់។ យើងខ្ញុំចង់សង្កត់ធ្ងន់ថា សេចក្តីណែនាំថ្មីនេះទទួលស្គាល់អំពីសារៈសំខាន់នៃការអនុវត្តការទិញនៅក្នុង CSDDD[6] ដែលនឹងដាក់ឱ្យអនុវត្តនាពេលខាងមុខនេះ។ មធ្យោបាយសំខាន់មួយសម្រាប់ការអនុវត្តការទិញដែលយកចិត្តទុកដាក់លើហានិភ័យ គឺជាការអនុវត្តកិច្ចសន្យាប្រកបដោយទំនួលខុសត្រូវ ដែលកំណត់អំពីទំនួលខុសត្រូវរបស់អ្នកផ្គត់ផ្គង់ និង អ្នកទិញដូចគ្នានៅក្នុង CSDD។ កិច្ចសន្យា[7] នេះទទួលស្គាល់នូវការរួមចំណែក ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដែលត្រូវការចាំបាច់ពីភាគីទាំងពីរក្នុងការដោះស្រាយហានិភ័យ និងផលប៉ះពាល់ដែលកើតឡើង ជាជាងការដាក់ទណ្ឌកម្ម។

- ➔ *(អនុសាសន៍ 2.1.) អ្នកទិញត្រូវអនុវត្តយកការអនុវត្តការទិញប្រកបដោយទំនួលខុសត្រូវ និងមានទំនុកចិត្តលើគ្នាទៅវិញទៅមក ការគោរព ការប្រាស្រ័យទាក់ទងប្រកបដោយតម្លាភាព និងលក្ខខណ្ឌពាណិជ្ជកម្មប្រកបដោយនិរន្តរភាព ជាមូលដ្ឋាននៃទំនាក់ទំនងពាណិជ្ជកម្មរបស់ខ្លួន។*
- ➔ *(អនុសាសន៍ 2.2.) និយ័តករត្រូវលើកកម្ពស់ដល់ការប្រើប្រាស់ប្រការនៃកិច្ចសន្យា និងពង្រឹងការអនុវត្តប្រការទាំងនោះ។ នៅក្នុងប្រការទាំងនេះ ចាំបាច់ត្រូវបង្កើតគោលការណ៍ "កំណត់ថ្លៃដើមប្រកបដោយនិរន្តរភាព"។*
- ➔ *(អនុសាសន៍ 2.3.) និយ័តករត្រូវលើកកម្ពស់ ប្រើប្រាស់ និងពង្រីកបទដ្ឋានមានស្រាប់ស្តីពីការអនុវត្តការទិញប្រកបដោយទំនួលខុសត្រូវ។*

## 3 លើកកម្ពស់កិច្ចសហការ និងការកែលម្អជាបន្តបន្ទាប់ ជាជាងការលុបបំបាត់ហានិភ័យ និងការដកខ្លួនចេញភ្លាមៗ

ការបង្កើននិយ័តកម្មនៅក្នុងដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDDD) នាំមកនូវហានិភ័យជាច្រើន ដែលក្រុមហ៊ុនបញ្ជាទិញនឹងព្យាយាមដកខ្លួនចេញពីប្រទេស ដើម្បីចៀសវាងហានិភ័យទាំងនោះ។ ទោះបីជាគោលការណ៍នេះមើលទៅហាក់ដូចជាបង្កការលំបាកតែចំពោះផ្នែកធុរកិច្ចយ៉ាងណាក្តី ប៉ុន្តែការអនុវត្តនេះអាចបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងធំធេងមកលើអ្នកផ្គត់ផ្គង់ និងសហគមន៍នៅក្នុងប្រទេសដែលត្រូវបានចាត់ថ្នាក់ជាប្រទេស "ដែលមានហានិភ័យខ្ពស់" ផងដែរ។ ដូចដែលមានចែងនៅក្នុង CSDDD ខាងមុខនេះ និងក្របខណ្ឌអន្តរជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ការដកខ្លួនចេញពីអ្នកផ្គត់ផ្គត់គួរតែជា "ជម្រើសចុងក្រោយ" ប៉ុណ្ណោះ នៅពេលដែលមិនអាចដោះស្រាយការរំលោភបំពានធ្ងន់ធ្ងរបាន[8]។ ទាំងក្រុមហ៊ុន និងភ្នាក់ងារអនុវត្តច្បាប់ចាំបាច់ត្រូវដាក់ចេញនូវវិធានការបង្ការ ដើម្បីកាត់បន្ថយហានិភ័យនៃការដកខ្លួនចេញភ្លាមៗ។

- ➔ *(អនុសាសន៍ 3.1.) អ្នកទិញចាំបាច់ត្រូវដឹងថា CSDD គឺមិនមែនធានាថាខ្សែច្រវាក់ផ្គត់ផ្គង់ទាំងអស់នឹងមិនមានហានិភ័យនោះទេ ប៉ុន្តែជាការយល់ដឹង និងការផ្សព្វផ្សាយអំពីហានិភ័យ ការរៀនសូត្រ និងការកែលម្អជាបន្តបន្ទាប់ ក៏ដូចជាការគាំទ្រដៃគូរបស់ខ្លួនឱ្យសម្របតាម CSDD។*
- ➔ *(អនុសាសន៍ 3.2.) អ្នកបង្កើតគោលនយោបាយត្រូវធានាឱ្យបានថា ការដកខ្លួនចេញដែលជា "ជម្រើសចុងក្រោយ" ត្រូវបានអនុវត្ត និងផ្តល់ការណែនាំបន្ថែមអំពីការចាកចេញប្រកបដោយទំនួលខុសត្រូវ និងលក្ខខណ្ឌនៃការដកខ្លួនចេញ ដែលការពារអ្នកផ្គត់ផ្គង់ពីផលវិបាកនៃការចាកចេញភ្លាមៗបែបនេះ។*

## 4 ពង្រឹងសិទ្ធិអំណាចអ្នកផ្គត់ផ្គង់ឱ្យអភិវឌ្ឍយុទ្ធសាស្ត្រ និងវិធីសាស្ត្រនិរន្តរភាពផ្ទាល់ខ្លួនចំពោះដំណើរការត្រឹមត្រូវនៃសិទ្ធិមនុស្ស និងបរិស្ថាន (HREDD)

វិធីសាស្ត្រជំរុញដោយអនុលោមភាពចំពោះ CSDD ជារឿយៗនាំឱ្យអ្នកទិញដាក់បន្ទុកលក្ខខណ្ឌតម្រូវលើអ្នកផ្គត់ផ្គង់ និងទាមទារឱ្យមានការធានាតាមកិច្ចសន្យាថា ខ្សែច្រវាក់ផ្គត់ផ្គង់របស់ខ្លួននឹងមិនមានហានិភ័យអ្វីនោះទេ។ វិធីសាស្ត្រនេះ មិនបានឆ្លុះបញ្ចាំងអំពីតថភាពពិតនៅក្នុងប្រទេសណាមួយនៅក្នុងពិភពលោកនោះទេ ព្រមទាំងមិនអនុញ្ញាតឱ្យមានការកែលម្អទៅលើចំណុចខ្វះខាត ឬការកែលម្អជាបន្តបន្ទាប់ឡើយ។ ជំនួសឱ្យការចូលរួមនៅក្នុងកិច្ចសន្ទនាប្រកបដោយតម្លាភាព និងមានផ្លែផ្កា អ្នកផ្គត់ផ្គង់មួយចំនួន ត្រូវបង្ខំចិត្តជ្រើសរើសលាក់បាំងហានិភ័យដើម្បីរក្សាបាននូវការបញ្ជាទិញ។

ការកសាងសមត្ថភាពរបស់អ្នកផ្គត់ផ្គង់ គឺតម្រូវចាំបាច់ដើម្បីជំរុញឱ្យពួកគេយល់ដឹង និងអនុវត្ត CSDD ក៏ដូចជាបង្កើតបាននូវការប្រាស្រ័យទាក់ទងប្រកបដោយតម្លាភាព និងទំនុកចិត្តរវាងអ្នកទិញ និងអ្នកផ្គត់ផ្គង់ផងដែរ។ ប្រការនេះចាប់ផ្តើមពីការយល់ដឹងអំពីហានិភ័យនៃធុរកិច្ច និងវិធានការដែលក្រុមហ៊ុនមានបំណងចង់អនុវត្តនៅក្នុងរយៈពេលខ្លី និងរយៈពេលវែង ដើម្បីដោះស្រាយហានិភ័យទាំងនេះ។

---

[6] សេចក្តីណែនាំស្តីពីដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្មរបស់សហភាពអឺរ៉ុប បុព្វកថា 46, 54 តម្រូវឱ្យក្រុមហ៊ុន "អភិវឌ្ឍ និងប្រើប្រាស់គោលនយោបាយទិញ ដែលរួមចំណែកដល់ប្រាក់ឈ្នួលចិញ្ចឹមជីវិត និងប្រាក់ចំណូលសម្រាប់អ្នកផ្គត់ផ្គង់ និងមិនជំរុញឱ្យមានផលប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស ឬបរិស្ថាន"

[7] https://www.responsiblecontracting.org/smcs

[8] Ibid. មាត្រា 11.7

បណ្ដាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH Network) ពង្រឹងសិទ្ធិអំណាចដល់អ្នកផ្គត់ផ្គង់ក្នុងការអភិវឌ្ឍវិធីសាស្ត្រផ្ទាល់ខ្លួនក្នុងការអនុវត្ត CSDD តាមរយៈការផ្ដល់ព័ត៌មាន ការប្រឹក្សា និងការផ្ដល់សេវាជំនាញការ។

- ➔ *(អនុសាសន៍ 4.1.) ដើម្បីធានាបាននូវការអនុវត្ត CSDD ប្រកបដោយប្រសិទ្ធភាព អ្នកផ្គត់ផ្គង់ចាំបាច់ត្រូវចេះបត់បែន ដើម្បីអាចមានលទ្ធភាពអភិវឌ្ឍយុទ្ធសាស្ត្រប្រកបដោយនិរន្តរភាពផ្ទាល់ខ្លួន និងប្រាស្រ័យទាក់ទងជាមួយអ្នកទិញអំពី CSDD បានដោយស្មើភាពគ្នា។*
- ➔ *(អនុសាសន៍ 4.2.) អ្នកបង្កើតគោលនយោបាយ ត្រូវផ្ដល់ការគាំទ្របន្ថែមអំពី CSDD សម្រាប់បណ្ដាប្រទេសផលិត ជាពិសេសសម្រាប់អាជ្ញាធរសាធារណៈ និងវិស័យឯកជន។*

> *"ការអនុវត្តដំណើរការត្រឹមត្រូវនៃសិទ្ធិមនុស្ស និងបរិស្ថាន (HREDD) គឺជាបញ្ហាច្រើនសណ្ឋាន ដែលទាមទារឱ្យមានការចាត់វិធានការដែលមានការសម្របសម្រួលគ្នាពីអ្នកធ្វើសេចក្ដីសម្រេចចិត្តផ្នែកនយោបាយ ស្ថាប័នម្ចាស់ជំនួយ និងតួអង្គសេដ្ឋកិច្ច។ មានតែកិច្ចសហការ និងទំនួលខុសត្រូវរួមប៉ុណ្ណោះ ទើបយើងអាចសម្រេចបាននូវលទ្ធផលប្រកបដោយអត្ថន័យ និងនិរន្តរភាព នៅក្នុងកិច្ចខិតខំប្រឹងប្រែងជាសកលក្នុងការការពារសិទ្ធិមនុស្សនិងបរិស្ថាន។"* – អ្នកគ្រប់គ្រងម្នាក់នៃអ្នកគ្រប់គ្រង RBH

## 5 ធានាបាននូវការគោរពតាមគោលនយោបាយ និងការប្រាស្រ័យទាក់ទងមានសង្គតិភាពអំពីលក្ខខណ្ឌតម្រូវផ្នែកច្បាប់

ដោយទិដ្ឋភាពផ្នែកច្បាប់នៅអឺរ៉ុបមានការវិវត្ត អ្នកទិញ ក៏ដូចជាអ្នកផ្គត់ផ្គង់ ជួបប្រទះនឹងលក្ខខណ្ឌតម្រូវថ្មីៗជាច្រើន ហើយជួនកាលលក្ខខណ្ឌតម្រូវខុសៗគ្នាក៏មានដែរ។ ក្រុមហ៊ុននានា ជាពិសេសក្រុមហ៊ុនមកពីប្រទេសផលិតកម្ម គឺទទួលរងនូវភាពលើសលុបដោយផ្នែក និងមានការភាន់ច្រលំដោយសារតែទំនាក់ទំនងគ្នានៃបទប្បញ្ញត្តិមួយចំនួននៅកម្រិតសហភាពអឺរ៉ុប។

ជាការសំខាន់ណាស់ក្នុងការទទួលស្គាល់ថា ទាំងអ្នកទិញ និងអ្នកផ្គត់ផ្គង់ គឺកំពុងតែស្ថិតក្នុងដំណាក់កាលនៃការស្វែងយល់អំពីលក្ខខណ្ឌតម្រូវទាំងនោះឱ្យបានយល់ច្បាប់។ ការយល់ដឹងអំពីចំណុចសំខាន់ៗនៃបទប្បញ្ញត្តិទាំងនេះ ទំនាក់ទំនងនៃបទប្បញ្ញត្តិទាំងនេះទៅនឹងក្របខណ្ឌច្បាប់របស់ខ្លួន និងការអនុវត្តវិធានការដែលត្រឹមត្រូវ គឺទាមទារឱ្យមានការចំណាយពេលវេលា និងធនធានច្រើន។

- ➔ *(អនុសាសន៍ 5.1.) និយ័តករមកពីសហភាពអឺរ៉ុប ត្រូវតែបញ្ជាក់ឱ្យបានច្បាស់អំពីភាពត្រួតគ្នា និងទំនាក់ទំនងគ្នានៃបទប្បញ្ញត្តិខ្សែច្រវាក់ផ្គត់ផ្គង់ថ្មី និងផ្សព្វផ្សាយអំពីប្រការទាំងនេះឱ្យមានសង្គតិភាព។*
- ➔ *(អនុសាសន៍ 5.2) និយ័តករ ត្រូវធានាឱ្យបាននូវការបន្សុីគ្នារវាងច្បាប់សហភាពអឺរ៉ុបស្ដីពី CSDD និងច្បាប់នៃបណ្ដាប្រទេសផ្សេងៗទៀត ដើម្បីឱ្យទិដ្ឋភាពច្បាប់អន្តរជាតិកាន់តែមានលក្ខណៈស្របគ្នា។*

--------------------------------------------------------------------------------------------------------------------

*<u>សេចក្ដីអំពាវនាវ</u>* – យើងខ្ញុំសូមអំពាវនាវឱ្យរដ្ឋាភិបាលនានា រួមបញ្ចូលអនុសាសន៍ខាងលើទៅក្នុងគោលការណ៍ណែនាំអនុវត្តបច្ចេកទេសច្បាប់ ឬលក្ខខណ្ឌតម្រូវថវិកានាពេលអនាគត និងអំពាវនាវឱ្យធុរកិច្ចនានារួមបញ្ចូលធាតុផ្សំទាំងនេះទៅក្នុងវិធានការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន និងសម្រេចបាននូវអត្ថប្រយោជន៍ដ៏មានអត្ថន័យ និងអត្ថប្រយោជន៍រួមនៃដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៃនិរន្តរភាពសាជីវកម្ម (CSDDD)។

ក្នុងនាមជាសមាជិកនៃបណ្ដាញមជ្ឈមណ្ឌលធុរកិច្ចប្រកបដោយការទទួលខុសត្រូវ (RBH Network) យើងខ្ញុំត្រៀមខ្លួនរួចរាល់ក្នុងការលើកកម្ពស់ការយល់ដឹង និងផ្ដល់ព័ត៌មានអំពីទិដ្ឋភាពច្បាប់ដែលមានការវិវត្តអំពីខ្សែច្រវាក់ផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព និងគាំទ្រដល់ធុរកិច្ចនានានៅក្នុងប្រទេសរបស់យើងខ្ញុំ។

# Signatories

RESPONSIBLE BUSINESS HUB CAMBODIA RBH NETWORK

EUROCHAM CAMBODIA

**RBH Cambodia**

20 September 2025 Phnom Penh

MARTIN BRISSON

*(Place, Date)* *(Name)*

RESPONSIBLE BUSINESS HUB BKMEA RBH NETWORK

BKMEA Working Today to Shine Tomorrow

**RBH Bangladesh**

Dhaka - 01 October 2024

Fazlee Shamim Ehsan,
Executive President, BKMEA

*(Place, Date)* *(Name)*

RESPONSIBLE BUSINESS HUB BGMEA RBH NETWORK

BGMEA

**RBH Bangladesh**

Dhaka, 10.10.2024

Abdullah Hil Rakib
Senior Vice President
BGMEA

*(Place, Date)* *(Name)*

**RBH Serbia**

Belgrade, 01.10.2024

*(Place, Date)*

Marko Čadež Digitally signed by Marko Čadež Date: 2024.10.01 15:47:02 +02'00'

*(Name)*

**RBH Tunisia**

24/10/2024

*(Place, Date)*

*(Name)*

**RBH Türkiye**

İstanbul, 11.10.2024

*(Place, Date)*

Arda Batu, Secretary General

*(Name)*